# សេចក្តីថ្លែងការណ៍របស់គណៈកម្មការប្រឹក្សាគម្រោង នៃគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា ការប្រជុំលើកទី៤៧

១/ នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៨ គណៈកម្មការប្រឹក្សាគម្រោង របស់អង្គការអន្តរជាតិខាងការងារ នៃគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា (BFC) បានជួបប្រជុំនៅទីក្រុងភ្នំពេញ ដើម្បីពិភាក្សាផ្តល់យោបល់លើសេចក្តីព្រាងបញ្ចប់អនុសាសន៍នៃរបាយការណ៍វាយតម្លៃពាក់កណ្តាលអណត្តរបស់ BFC ក៏ដូចជាការជជែកស្វែងរកយន្តការបន្តពង្រឹងនៃកម្មវិធីរបាយការណ៍តម្លាភាពឱ្យកាន់តែប្រសើរ។ គណៈកម្មការប្រឹក្សាគម្រោង មានសមាសភាពតំណាងមកពីរាជរដ្ឋាភិបាលកម្ពុជា (ក្រសួងការងារ និងបណ្តុះបណ្តាលជីវៈ និងក្រសួងពាណិជ្ជកម្ម) និយោជក (សមាគមរោងចក្រកាត់ដេរនៅកម្ពុជា GMAC) និងកម្មករនិយោជិត (តំណាងមកពីសហភាព និងសហព័ន្ធផ្សេងៗ)។

២/ យើងខ្ញុំដែលជាសមាជិកគណៈកម្មការប្រឹក្សាគម្រោង សូមស្វាគមន៍ទៅនឹងលទ្ធផលពង្រាងបញ្ចប់អនុសាសន៍នៃរបាយការណ៍វាយតម្លៃពាក់កណ្តាលអណត្តរបស់ BFC នេះ។ យើងទទួលស្គាល់នូវលទ្ធផលដ៏មានសារៈសំខាន់របស់កម្មវិធីដែលបានបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជានៅឆ្នាំ២០០១ ក្នុងភាពជាដៃគូជាមួយអង្គការអន្តរជាតិខាងការងារ (ILO) និងការគាំទ្រដល់អណត្តរបស់ BFC តាមរយៈសារាចរណែនាំស្តីពីការអនុវត្តន៍គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជានៅឆ្នាំ២០០៥ដើម្បីធ្វើឱ្យប្រសើរឡើងដល់វិស័យវាយនភ័ណ្ឌ និងសំលៀកបំពាក់។ ដូចមានចែងនៅក្នុងសេចក្តីប្រកាស តាមរយៈការអនុវត្តគម្រោងដែលសមាជិកភាពជាតម្រូវការមួយចំពោះរោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញទាំងអស់ យើងទទួលស្គាល់ថាប្រទេសកម្ពុជា គឺត្រូវធានានូវច្បាប់ការងារ និងបទបញ្ញាផ្សេងទៀតត្រូវបានអនុវត្តឱ្យមានប្រសិទ្ធភាពដោយផ្តល់នូវគុណភាពកន្លែងធ្វើការប្រកបដោយសុវត្ថភាព និងផាសុភាពខ្ពស់ ហើយបង្កើននូវតម្លាភាពនៅក្នុងការគ្រប់គ្រងច្បាប់ការងារ ជាពិសេសគឺធ្វើឱ្យប្រសើរឡើងនូវភាពអនុលោមការងារ និងបន្តជម្រុញឱ្យមានការអនុវត្តច្បាប់ បទបញ្ញា សិទ្ធការងារទូទៅដែលមានស្រាប់ដូចមាន ចែងនៅក្នុងច្បាប់ការងាររបស់ប្រទេសកម្ពុជា។

៣/ យើងយល់ស្របនឹងការរកឃើញនៃការវាយតម្លៃទាក់ទងនឹងលទ្ធផលដែលកម្មវិធីនេះដែលបានរួមចំណែកនៅក្នុងវិស័យកាត់ដេរ និងកម្មកររួមមាន៖

- ក) រួមចំណែកដល់កំណើនទូទៅនៃវិស័យកាត់ដេរ
- ខ) ធ្វើអោយប្រសើរឡើងនូវជីវភាពរបស់កម្មករយ៉ាងតិចកន្លះលាននាក់នៅក្នុងគម្រោងរបស់BFC រួមទាំងសមាជិកក្រុមគ្រួសាររបស់ពួកគេជាច្រើនទៀត ។
- គ) ធានាថាកម្មករនិយោជិតទទួលបានប្រាក់ឈ្នួលសមរម្យ ត្រឹមត្រូវ និងអត្ថប្រយោជន៍គាំពារសង្គមនានា
- ឃ) កាត់បន្ថយករណីពលកម្មកុមារ

ង) ធ្វើឱ្យរោងចក្រកាត់ដេរនៅកម្ពុជាកាន់តែមានសុវត្ថិភាព

ច) ការបង្កើតឱ្យមានការគិតគូដល់លក្ខខណ្ឌការងារកាន់តែប្រសើរនៅក្នុងវិស័យកាត់ដេរសំលៀកបំពាក់

ឆ) ជម្រុញការអនុវត្តរបស់និយោជកតាមរយៈ ១) ការប្រើប្រាស់ព័ត៌មានរបស់រោងដើម្បីកំណត់ទិសដៅក្នុងការធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារ និង ២) ជាផ្នែកស្នូលនៃយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យរបស់អ្នកបញ្ជាទិញ។

៤/ យើងយល់ស្របនឹងសេចក្តីព្រាងនៃអនុសាសន៍វាយតម្លៃពាក់កណ្តាលអណត្តរបស់BFC ហើយនៅខណៈពេលរង់ចាំរបាយការណ៍វាយតម្លៃចុងក្រោយ យើងក៏នឹងគាំទ្រការអនុវត្តន៍យុទ្ធសាស្ត្របច្ចុប្បន្ន និងអនាគតរបស់កម្មវិធីក្នុងការលើកកម្ពស់សិទ្ធិការងារនៅកម្ពុជា។

៥/ យើងក៏រីករាយផងដែរដោយការកត់សម្គាល់ឃើញថា កម្ពុជាបានដើរតួនាទីឈានមុខគេក្នុងការដាក់ឱ្យមានរបាយការណ៍តម្លាភាពក្នុងឆ្នាំ២០១៤ ហើយកម្មវិធីការងារកាន់តែប្រសើររបស់បណ្តាប្រទេសផ្សេងទៀតក៏បានអនុវត្តតាមភាពជោជ័យនេះដែរនៅក្នុងឆ្នាំ២០១៧។ យើងនឹងស្វែងយល់បន្ថែមទៀតថាតើគួរដាក់បញ្ចូលបញ្ហាចម្បងៗផ្សេងទៀតឱ្យដូចបណ្តាប្រទេសនៃកម្មវិធីការងារកាន់តែប្រសើរឬយ៉ាងណារវាងគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជាដើម្បីធានាថាកម្ពុជានៅតែជាអ្នកដឹកនាំលើគំនិតផ្តួចផ្តើមដ៏សំខាន់នេះ។

៦/ យើងរីករាយជាមួយនឹងលទ្ធផលជាវិជ្ជមាននៃរបាយការណ៍តម្លាភាព ជាពិសេសករណីសុខភាព និងសុវត្ថភាពការងារហើយយើងក៏យល់ស្របចំពោះមតិយោបល់បន្ថែមនានាក្នុងករណីនៃបញ្ហាចម្បងៗមួយចំនួន ក៏ដូចជាបញ្ហារោងចក្រដែលមានអនុលោមតាមច្បាប់ការងារទាប។ យើងស្វាគមន៍នូវកិច្ចសហការបន្តជាមួយ BFC ដើម្បីធានាថាបញ្ហាចម្បងៗទាំងអស់នឹងត្រូវបានដោះស្រាយ ហើយចំនួនរោងចក្រដែលមានអនុលោមតាមច្បាប់ការងារទាបត្រូវបានកាត់បន្ថយ។ ជាមួយនឹងកិច្ចសហការនាពេលអនាគតនេះដែរ យើងគួរដាក់បញ្ចូលរួមគ្នានៃការងារត្រួតពិនិត្យលក្ខខណ្ឌការងាររបស់ BFC និងតួនាទីការធ្វើរបាយការណ៍ និងការទទួលខុសត្រូវរវាងត្រីភាគីរួមមាន៖

ក) តួនាទីរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការពង្រឹងនូវការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធភាព

ខ) តួនាទីរបស់សមាគមរោងចក្រកាត់ដេរនៅកម្ពុជា GMAC ក្នុងការជូនដំណឹងដល់សមាជិក និងផ្តល់ការបណ្តុះបណ្តាលពួកគេអំពីច្បាប់ការងារ ហើយអនុវត្តឱ្យមានគណនេយ្យភាពនៅពេលមានករណីឬហេតុការណ៍ អ្វីមួយកើតឡើង

គ) តួនាទីរបស់សហជីព ក្នុងការផ្តល់ព័ត៌មានទៅកាន់សមាជិករបស់ពួកគេអំពីសិទ្ធិ និងការទទួលខុសត្រូវ ហើយគាំទ្រក្នុងការរកដំណោះស្រាយដោយសន្តិវិធី
ជាមួយអ្នកគ្រប់គ្រង/និយោជកនៅពេលកើតមានបញ្ហា នានានៅក្នុងរោងចក្រ។

៧/ គណៈកម្មការប្រឹក្សាគម្រោង សូមអំពាវនាវដល់អ្នកបញ្ជាទិញទាំងឡាយ និងសហគមន៍អន្តរជាតិឱ្យបន្តគាំទ្រឧស្សាហកម្មនេះ និងគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា (BFC) សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច ឧស្សាហ៍កម្ម និងការអភិវឌ្ឍន៍សង្គម បន្ថែមទៀតដល់ប្រទេសកម្ពុជា និងកម្មករនិយោជិតទាំងអស់។ ដោយទទួលស្គាល់នូវភាពរីកចំរើន និងការរួមចំណែកធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារនៅក្នុងវិស័យនេះ រួមជាមួយ BFC យើងសូមឱ្យសហគមន៍អន្តរជាតិបន្តការគាំទ្រប្រទេសកម្ពុជា ជាពិសេសនោះគឺការអនុគ្រោះដល់ទីផ្សារនាំចូល។ ការគាំទ្រទាំងនេះគឺមានសារៈសំខាន់ខ្លាំងណាស់ដើម្បីធានា និងបន្តភាពរីកចំរើននូវលក្ខខណ្ឌការងារល្អដល់ កម្មករនិយោជិត។

៨/ គណៈកម្មការប្រឹក្សាគម្រោង សូមលើកទឹកចិត្តដល់អ្នកបញ្ជាទិញទាំងឡាយ ក្នុងការដើរតួនាទីឱ្យកាន់តែមានតម្លាភាពដើម្បីធានាកន្លែងធ្វើការនៅក្នុងរោងចក្រត្រូវបានអនុលោមតាមច្បាប់ការងារ ហើយការរាយការណ៍ជាសាធារណៈនូវបញ្ជីឈ្មោះរោងចក្ររបស់ខ្លួន និងឥរិយាបទនៃការបញ្ជាទិញពីប្រទេសផ្សេងៗ។

៩/ ជាថ្មីម្តងទៀត យើងខ្ញុំសូមគាំទ្រយ៉ាងពេញលេញដល់គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា និងអំពាវនាវភាគីពាក់ព័ន្ធទាំងអស់ក្នុងកិច្ចខិតខំកិច្ចប្រឹងប្រែងរបស់ខ្លួនទ្វេរដង ដើម្បីធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារនៅក្នុងវិស័យកាត់ដេរនៅកម្ពុជាបន្ថែមទៀត។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៨